**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ បប

# បទបញ្ជា

## ស្តីពី

## ការអភិរក្ស និងអភិវឌ្ឍន៍ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ

សត្វផ្សោតទន្លេមេគង្គជាប្រភេទសត្វផ្សោតដ៏កម្រមួយនៅលើពិភពលោកដែលបច្ចុប្បន្នកំពុងប្រឈមមុខ នឹងការគំរាមកំហែង និងឈានទៅរកការវិនាសសាបសូន្យ ប្រសិនបើគ្មានវិធានការការពារ និងអភិរក្សអោយបានទាន់ពេលវេលា និងប្រសិទ្ធភាព ។

យោងលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០០៤ និងឆ្លងតាមកិច្ចពិភាក្សា និងសំណូមពរនានា នៃសិក្ខាសាលាជាតិស្តីពីការអភិរក្ស និងអភិវឌ្ឍន៍ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ នាថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ រាជរដ្ឋាភិបាលចេញបទបញ្ជាដូចខាងក្រោម :

១-ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីចាត់វិធានការយ៉ាងតឹងរឹង ហាមឃាត់ការនេសាទដោយប្រើប្រាស់មងគ្រប់ប្រភេទ ទប់ស្កាត់ចំពោះបទល្មើសនេសាទដោយប្រើឧបករណ៍ឆក់ គ្រឿងផ្ទុះ ក្បូនឫស្សី ក្បូនឈើដែលបាននឹងកំពុងធ្វើសកម្មភាពក្នុងតំបន់ និងឆ្លងកាត់តំបន់ដែលមានសត្វផ្សោតរស់នៅ ចាប់ពីតំបន់កំពី ខេត្តក្រចេះ ដល់ព្រំដែនកម្ពុជា-ឡាវ ក្នុងខេត្តស្ទឹងត្រែង ។

២-ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវសិក្សា និងណែនាំអំពីបច្ចេកទេសជំនាញនៃការដាក់សំណាញ់គ្របស្លាបចក្រជលយានយន្តដល់ម្ចាស់ជលយានយន្តគ្រប់ប្រភេទអោយអនុវត្ត ។ ព្រមជាមួយនេះត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ពន្ធ័ និងអាជ្ញាធរដែនដីដើម្បីដាក់ផ្លាកសញ្ញាចរាចរផ្លូវទឹក និងធ្វើការណែនាំដល់អ្នកបើកបរកាណូតធំ និងកាណូតលឿនគ្រប់ប្រភេទដែល ធ្វើដំណើរឆ្លងកាត់តំបន់សត្វផ្សោតរស់នៅនេះត្រូវបន្ថយល្បឿន និងសំលេង ព្រមទាំងហាមដាច់ខាតក្នុងការបង្ហូរប្រេងម៉ាស៊ីន និងកាកសំណល់ផ្សេងៗគ្រប់ប្រភេទចូលក្នុងទឹកទន្លេ ដើម្បីការពារបរិស្ថានជាពិសេសក្នុងតំបន់សត្វផ្សោតរស់នៅ ។

៣-ក្រសួងបរិស្ថានសហការជាមួយក្រសួងពាក់ពន្ធ័ និងអាជ្ញាធរដែនដីចាត់វិធានការណែនាំ អប់រំអំពីការថែរក្សាអនាម័យ និងទប់ស្កាត់ជាបន្ទាន់ការបង្ហូរកាកសំណល់នានាចូលទន្លេដែលធ្វើអោយខូចបរិស្ថាន ជាពិសេសក្នុងតំបន់មានសត្វផ្សោតរស់នៅ ។

៤-ក្រសួងទេសចរណ៍ត្រូវយកចិត្តទុកដាក់គិតគូរដល់ការអប់រំបណ្តុះបណ្តាលមគ្គុទេសក៍ទេសចរ គ្រប់គ្រងនិងលើកកំពស់គុណភាពសេវាទេសចរណ៍នៅតំបន់នេះអោយបានល្អ ។

៥-អាជ្ញាធរជាតិទេសចរណ៍ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើការឃោសនា អប់រំដល់មហាជនគ្រប់មជ្ឈដ្ឋាន និងប្រជាជននៅតាមសហគមន៍មូលដ្ឋានអោយបានទូលំទូលាយ និងស៊ីជំរៅ ។ ទន្ទឹមនឹងនេះត្រូវសហការជាមួយអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធរៀបចំចាត់តាំងការិយាល័យពីរកន្លែងនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដើម្បីជាយន្តការអចិន្ត្រៃយ៍ដឹកនាំការងារនេះ និងត្រូវបង្កើតក្រុមល្បាតចល័តជាបន្ទាន់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសទាំងឡាយដែលធ្វើអោយវិនាសអន្តរាយដល់ជីវិតសត្វផ្សោត អោយមានប្រសិទ្ធភាព ។

៦-ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីនៃខេត្តក្រចេះ និងខេត្តស្ទឹងត្រែងត្រូវបង្កើនការយកចិត្តទុកដាក់ជួយដល់ *អាជ្ញាធរជាតិទេសចរណ៍កម្ពុជា* ក្នុងការអភិរក្សផ្សោតទន្លេមេគង្គ និងអភិវឌ្ឍន៍ទេសចរណ៍ ចាប់ពីតំបន់កាំពី ខេត្តក្រចេះរហូតដល់ព្រំដែនកម្ពុជា-ឡាវក្នុងខេត្តស្ទឹងត្រែង ដើម្បីចូលរួមចំណែកក្នុងការ កាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ ។

៧-ជនណាដែលប្រព្រឹត្តផ្ទុយពីបទបញ្ជានេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ទទួលបានបទបញ្ជានេះ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរជាតិទេសចរណ៍កម្ពុជា អភិបាលខេត្តក្រចេះ អភិបាលខេត្តស្ទឹងត្រែង និងអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តបទបញ្ជានេះអោយមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន** :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-សាលាខេត្តក្រចេះ និងខេត្តស្ទឹងត្រែង

-ឯកសារ-កាលប្បវត្តិ